ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៥៤៣ អយក.ប្រក

# ប្រកាស
# ស្ដីពី
# ការដាក់ឱ្យអនុវត្តនូវកម្រងភារកិច្ចគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរលេខ ០៨ សរ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរក្សាសណ្ដាប់ធ្នាប់របៀបរៀបរយនៅពេលប្រឡង
- បានឃើញប្រកាសលេខ ២៧៨៦ អយក.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៩ ស្ដីអំពីបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសាធារណៈ
- បានឃើញប្រកាសលេខ ១១០ អយក.ប្រក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
- យោងតាមការចាំបាច់ របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវកម្រងភារកិច្ចគណៈមេប្រយោគ និងគណៈកម្មការផ្សេងៗ សម្រាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដូចខាងក្រោមៈ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- គណៈកម្មការកោសល្យវិច័យ
- គណៈមេប្រយោគទូទាំងប្រទេសសំណេរ
- គណៈកម្មការអប្បមាទទូទាំងប្រទេស
- ប្រធាន អនុប្រធានមណ្ឌលសំណេរ
- គណៈកម្មការកណ្ដាលមណ្ឌលសំណេរ
- គណៈកម្មការត្រួតពិនិត្យតាមអគារ
- គណៈកម្មការអនុរក្ស
- គណៈមេប្រយោគទូទាំងប្រទេសកំណែ
- ប្រធាន អនុប្រធានមណ្ឌលកំណែ
- គណៈកម្មការក្រុមមុខវិជ្ជា
- គណៈកម្មការកណ្ដាលមណ្ឌលកំណែ
- គណៈកម្មការអប្បមាទមណ្ឌលកំណែ
- គណៈកម្មការត្រួតពិនិត្យបច្ចេកទេសកំណែ
- គណៈកម្មការកំណែ
- គណៈកម្មការបែងចែកសន្លឹកកិច្ចការ
- គណៈកម្មការប្រចាំមណ្ឌលកំណែ
- គណៈកម្មការផលិត ប្តូរសន្លឹកសម្រង់ពិន្ទុ (MCS) និងផ្គត់ផ្គង់សម្ភារៈ
- អនុគណៈកម្មការគ្រប់គ្រងសន្លឹកសម្រង់ពិន្ទុ (MCS)
- អនុគណៈកម្មការគ្រប់គ្រងទិន្នន័យ
- អនុគណៈកម្មការអនុរក្ស (សម្រាប់ដំណើរការស្រង់ បូកពិន្ទុ)
- អនុគណៈកម្មការបញ្ចូលពិន្ទុ
- អនុគណៈកម្មការផ្ទៀងផ្ទាត់

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៣.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៤

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាលារាជធានី ខេត្ត
- អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ នា.មចទ